ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៨១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម រាជធានីភ្នំពេញ អាណត្តិទី៤ លើកទី១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា២ និងមាត្រា១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីរបៀបរបបនិងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៦១ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា១០ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីរបៀបរបបនិងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

# សម្រេច

**មាត្រា១.-**

ត្រូវបានទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ចំនួន៤០(សែសិប) រូប សម្រាប់អាណត្តិទី៤ លើកទី១ ដែលបែងចែកតាមប្រភេទអាជីវកម្មដូចខាងក្រោម៖

**ប្រភេទពាណិជ្ជកម្ម**

| | | | | | |
|---|---|---|---|---|---|
| ១- | អ្នកឧកញ៉ា | **គិត ម៉េង** | ៧- | ឧកញ៉ា | **ស៊ីវ ថៃ** |
| ២- | ឧកញ៉ា | **លី ហួរ** | ៨- | ឧកញ៉ា | **អ៊ីង សែ** |
| ៣- | ឧកញ៉ា | **ហ៊ុន ឡាក់** | ៩- | ឧកញ៉ា | **អ៊ុន យុទ្ធី** |
| ៤- | ឧកញ៉ា | **គីម សាឌុច** | ១០- | ឧកញ៉ា | **ហេង សិទ្ធី** |
| ៥- | លោកស្រីឧកញ៉ា | **កែវ មុំ** | ១១- | ឧកញ៉ា | **លី យុនថៃ** |
| ៦- | លោកជំទាវឧកញ៉ា | **លីម ឈីវហួរ** | ១២- | ឧកញ៉ា | **លីម ប៊ុនសេង** |

**ប្រភេទឧស្សាហកម្ម**

| | | | | | |
|---|---|---|---|---|---|
| ១- | ឧកញ៉ា | **ស៊ិន សុខណា** | ៧- | ឧកញ៉ា | **ហាន់ ឃៀង** |
| ២- | ឧកញ៉ា | **ផេ ហុកឈួន** | ៨- | ឧកញ៉ា | **ថៃ ជាហួត** |
| ៣- | ជំទាវឧកញ៉ាបណ្ឌិត | **កែវ ម៉ាលី** | ៩- | ឧកញ៉ា | **ប៊ុន ហៃ** |
| ៤- | លោកបណ្ឌិត | **តាន់ មុនីវណ្ណ** | ១០- | ឧកញ៉ា | **លី ហុង** |
| ៥- | ឧកញ៉ា | **តែ តាំងប៉ះ** | ១១- | លោកស្រីឧកញ៉ា | **ចាន់ សុទ្ធា** |
| ៦- | លោក | **គីម ម៉េងហ៊ួត** | ១២- | ឧកញ៉ា | **តែ អ៊ីវែ** |

**ប្រភេទសេវាកម្ម និងមិជ្ជាជីវៈសេរី**

| | | | | | |
|---|---|---|---|---|---|
| ១- | ឧកញ៉ា | **សុខ ពិសិដ្ឋ** | ៦- | ឧកញ៉ា | **ធី ពិសិដ្ឋ** |
| ២- | ឧកញ៉ា | **គួច ផេង** | ៧- | ឧកញ៉ា | **សុខ ឆេង** |
| ៣- | លោក | **លីម សុជាតិ** | ៨- | ឯកឧត្តម | **គុជ ស៊ីនិត** |
| ៤- | ឧកញ៉ា | **ចិញ្ញ ហ៊ួរ** | ៩- | ឯកឧត្តមឧកញ៉ា | **ហ៊ី បាវី** |
| ៥- | លោក | **គុយ វ៉ាត** | ១០- | ឧកញ៉ា | **សុ ខុន** |

**ប្រភេទកសិកម្ម**

| | | | | | |
|---|---|---|---|---|---|
| ១- | អ្នកឧកញ៉ា | **ហុង ពីវ** | ៤- | ឧកញ៉ា | **អាន ម៉ាឌី** |
| ២- | ឧកញ៉ា | **តាំង គួង** | ៥- | ឧកញ៉ា | **លីម ហេង** |
| ៣- | ឧកញ៉ា | **ណាង សុធី** | ៦- | ឧកញ៉ាបណ្ឌិត | **តាន់ គីមមេង ។** |

**មាត្រា២.-**

ត្រូវបានទទួលស្គាល់ **អ្នកឧកញ៉ា គិត ម៉េង** ជាប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ សម្រាប់អាណត្តិទី៤ លើកទី១។

**មាត្រា៣.-**

អនុក្រឹត្យលេខ២៣៧ អនុក្រ.តត ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០ ស្តីពីការទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មរាជធានីភ្នំពេញ អាណត្តិទី៤ លើកទី១ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអាទិត្យ ៧រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-រដ្ឋបាលរាជធានីភ្នំពេញ
-សភាពាណិជ្ជកម្មកម្ពុជា
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ